# ដំណឹងជ្រើសរើសបុគ្គលិក

មេហ្គាលីស៊ីង ភីអិលស៊ី
MEGA LEASING PLC.

**មេហ្គាលីស៊ីង ភីអិលស៊ី** គឺជាគ្រឹះស្ថានផ្តល់សេវាកម្មភតិសន្យាហិរញ្ញវត្ថុដែលត្រូវ បានបង្កើតឡើងនៅក្នុងឆ្នាំ ២០១៣ និងទទួលបានអាជ្ញាប័ណ្ណជាផ្លូវការ ពីធនាគារជាតិនៃកម្ពុជា នៅក្នុងខែមករា ឆ្នាំ ២០១៤។ បេសកកម្មរបស់គ្រឹះស្ថាន មេហ្គាលីស៊ីង ភីអិលស៊ី គឺផ្តល់សេវាកម្មហិរញ្ញវត្ថុឆាប់រហ័ស ដើម្បីឆ្លើយតបតាមតម្រូវការរបស់អតិថិជន ជាពិសេសទៅលើផលិតផលសម្រាប់ប្រើប្រាស់ និងសម្រាប់អាជីវកម្ម រួមមាន រថយន្តម៉ូតូ, កង់, ឧបករណ៍អេឡិចត្រូនិក គ្រឿងប្រើប្រាស់ក្នុងផ្ទះ គ្រឿងសង្ហារឹម និងឧបករណ៍ និងគ្រឿងចក្របម្រើឲ្យវិស័យកសិកម្ម។ ដើម្បីឆ្លើយតបនឹងការរីកចម្រើនរបស់ខ្លួន ក្រុមហ៊ុនត្រូវការជ្រើសរើសមុខតំណែងដូចព័ត៌មានលំអិតខាងក្រោម៖

**មុខតំណែង:** មន្ត្រីឥណទាន (៣០នាក់)

**ទីតាំងជ្រើសរើស:**
- **សាខាភ្នំពេញ** (០២)
- **ខេត្តកណ្តាល** (០២) ចំការដូង (០២)
- **ត្បូងឃ្មុំ** (០២) **ស្វាយអន្ទរ** (០២) មេមត់ (០២)
- **កំពង់ចាម** (០២) ចំការលើ (០២)
- **បាត់ដំបង** (០២) មោងឫស្សី (០២)
- **បន្ទាយមានជ័យ** (០២)
- **សៀមរាប** (០២) ជីក្រែង (០២) ពួក (០២)
- **ព្រះសីហនុ** (០២)

**កាលបរិច្ឆេទឈប់ទទួលពាក្យ:** **ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨**

## ភារកិច្ច និងការទទួលខុសត្រូវ៖

- ត្រូវស្វែងរកអតិថិជនល្អៗដែលមានបំណងក្នុងការប្រើប្រាស់សេវាកម្មបង់រំលស់របស់ មេហ្គាលីស៊ីង ភីអិលស៊ីង
- ចុះវាយតំលៃប្រាក់កម្ចី ផ្អែកតាមគោលការណ៍ឥណទានរបស់ក្រុមហ៊ុន
- វិភាគពីតម្រូវការឥណទាន និងសេវាឥណទានរបស់ដៃគូប្រកួតប្រជែង នៅក្នុងតំបន់ប្រតិបត្តិការ
- ពង្រីកការផ្សព្វផ្សាយ ផលិតផលសេវាកម្មរបស់ក្រុមហ៊ុននៅខាងក្នុង និងជុំវិញតំបន់ប្រតិបត្តិការ
- រៀបចំឯកសារស្នើសុំនិងបង្រៀនណែនាំអតិថិជនពីគោលការណ៍ និងលក្ខខណ្ឌនានារបស់ក្រុមហ៊ុន
- ពិនិត្យ និងតាមដានការប្រើប្រាស់ផលិតផល និងត្រួតពិនិត្យការបង់សងត្រឡប់របស់អតិថិជន
- ចាត់វិធានការដោះស្រាយជាមួយអតិថិជន ក្នុងករណីមានការខកខានក្នុងការបង់សងត្រឡប់
- និងសុំជំនួយពីបុគ្គលិក ផ្នែកដោះស្រាយបំណុលក្នុងករណីចាំបាច់។
- មានការចូលរួមគ្រប់សកម្មភាពក្នុងដំណើរការអាជីវកម្មរបស់ក្រុមហ៊ុន
- កសាងទំនាក់ទំនងល្អជាមួយអតិថិជន និងអាជ្ញាធរមូលដ្ឋានក្នុងបំណងប្រតិបត្តិការ

## លក្ខខណ្ឌជ្រើសរើស៖

1. បរិញ្ញាបត្រផ្នែកគណនេយ្យ រឺហិរញ្ញវត្ថុ រឺ ធនាគារ
2. មានបទពិសោធន៍ការងារពាក់ព័ន្ធនឹងវិស័យធនាគារ មីក្រូហិរញ្ញវត្ថុ(MFI) ឬភតិសន្យាហិរញ្ញវត្ថុ(ការបង់រំលស់) កាន់តែប្រសើរ
3. មានចំណេះដឹងផ្នែក កុំព្យូទ័រ និង ភាសាអង់គ្លេសកាងារជាក្រុមមានទំនាក់ទំនងល្អ និង ជំនាញធ្វើ ,
4. ចេះគ្រប់គ្រងបានយ៉ាងល្អនៅលើភារកិច្ចការងារពហុ/និងការងារដែលមានការកំណត់ ពេលវេលា ព្រមទាំងការងារដែលមានសម្ពាធ
5. មានសីលធម៌ល្អ ឥរិយាបថល្អ ស្មោះត្រង់ ការប្តេជ្ញាចិត្ត អត់ធ្មត់ខ្ពស់ និងមានការគោរពវិន័យ
6. មានជំនាញក្នុងការប្រាស្រ័យទាក់ទង ការផ្សព្វផ្សាយ ការវិភាគ និងការគណនា
7. មានម៉ូតូផ្ទាល់ខ្លួន ដែលអាចប្រើប្រាស់ផ្លូវឆ្ងាយបាន
8. មានទីលំនៅក្នុងតំបន់ប្រតិបត្តិការ ឬនៅជិតតំបន់ប្រតិបត្តិការជាអាទិភាព

ធ្វើឲ្យជីវិតទាន់សម័យ

ក្រុមហ៊ុន **មេហ្គាលីស៊ីង ភីអិលស៊ី** និងធ្វើការផ្តល់ប្រាក់បៀវត្សក្នុងលក្ខណៈប្រកួតប្រជែង និង មានកំណើនទៀងទាត់ប្រចាំឆ្នាំ។ មានផ្តល់ប្រាក់ឧបត្ថម្ភ ចូលឆ្នាំខ្មែរ និង បុណ្យភ្ជុំបិណ្ឌ, ប្រាក់លើកទឹកចិត្ត, ប្រាក់សោធននិវត្តន៍ ការធានារ៉ាប់រងសុខភាព និង គ្រោះថ្នាក់ 24 ម៉ោង , ធានារ៉ាប់រងអាយុជីវិត និង មានការឈប់សម្រាកស្របទៅតាមច្បាប់ការងាររួមទាំងអត្ថប្រយោជន៍ផ្សេងៗជាច្រើនទៀត។

**ប្រសិនបើបេក្ខជននិងបេក្ខនារីមានចំណាប់អារម្មណ៍ អាចផ្ញើប្រវត្តិរូបសង្ខេប និងលិខិតអម (CV and Cover letter) ព្រមទាំងថតចម្លងឯកសារដូចខាងក្រោម៖**

- សញ្ញាបត្រដែលទទួលបាន ឬ លិខិតបញ្ជាក់ការសិក្សាពីសាកលវិទ្យាល័យ
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬ ឯកសារដែលមានតំលៃស្មើ
- សៀវភៅគ្រួសារ និង សំបុត្របញ្ជាក់កំណើត

សូមផ្ញើមកកាន់នាយកដ្ឋានធនធានមនុស្ស មេហ្គាលីស៊ីង ភីអិលស៊ីតាមរយៈ **អាស័យដ្ឋាន ផ្ទះលេខ៦៧ ផ្លូវលេខ១២៥ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ឬផ្ញើមកតាមរយៈ អ៊ីមែល៖** recruitment@megaleasing.com.kh ឬ ព័ត៌មានបន្ថែមអាចទាក់ទងតាមរយៈ**ទូរសព្ទ៖ ០៦៩ ៥២២ ៥២២/០៦៩ ៣៦៤ ៦៦៦/០៦៩ ៦៤៤ ៨៨៨**

សាខា**ខេត្តត្បូងឃ្មុំ**តាមរយៈ អាស័យដ្ឋាន ភូមិសួងលិច, សង្កាត់សួង, ក្រុងសួង, ខេត្តត្បូងឃ្មុំ ទូរសព្ទ៖ ០៦៩ ៣២២ ៨៨៨។

សាខា**ខេត្តកំពង់ចាម:** ភូមិបឹងស្នាយ, សង្កាត់សំបូរមាស, ក្រុងកំពង់ចាម, ខេត្តកំពង់ចាម ទូរសព្ទ៖ ០៦៩ ៣២២ ៨៨៨។

សាខា**ខេត្តសៀមរាប**: ផ្ទះលេខ ៣១៤A, ផ្លូវលោកតាណឹយ,ក្រុមទី១១, ភូមិបន្ទាយចាស់, សង្កាត់ស្លក្រាម, ក្រុងសៀមរាប, ខេត្តសៀមរាប ទូរសព្ទ៖០៦៩ ៩៣០ ៦៦៦

សាខា**ខេត្តព្រះសីហនុ:** ផ្លូវបុរីកម្មករ(សេតេ), ភូមិ២, សង្កាត់៣, ក្រុងព្រះសីហនុ, ខេត្តព្រះសីហនុ ទូរស័ព្ទ៖ ០៦៩ ៤៤០ ៤៤៤

សាខា**ខេត្តបន្ទាយមានជ័យ:** ផ្ទះលេខ ៣៥០, ផ្លូវលេខ ៥៦A, សង្កាត់កំពង់ស្វាយ, ក្រុង សេរីសោភណ្ឌ, ខេត្តបន្ទាយមានជ័យ, ទូរស័ព្ទ៖ ០៦៩ ៦០០ ៨៨៨

សាខា**ខេត្តបាត់ដំបង:** ផ្ទះលេខ ១២-១៣, ភូមិអូរតាគាំ១, សង្កាត់ទួលតាឯក, ក្រុងបាត់ដំបង, ខេត្តបាត់ដំបង ទូរស័ព្ទ៖ ០៦៩ ៩៨០ ៦៦៦